ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៥៨/១២-ឌីកនើធី នីតធើរ

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីតធីត**

អាសយដ្ឋាន ៖ ភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៦៧ ៩៩៩ ៨៩៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក តាំង ស៊ុនហេង | រដ្ឋបាល |
| ២- លោក Jiang Wei | ប្រធានផលិតកម្ម |
| ៣- លោក ឡុង ហ៊ាង | តំណាង GMAC |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ឌីកនើធី នីតធើរ**

អាសយដ្ឋាន ៖ ភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៩២ ៤៩៤ ៧០៧ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក មូ ឈាង មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

២- លោក ភិន សុភា ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ

៣- លោក ចឹក ប៊ុនសាន អនុប្រធានសហជីព

៤- លោក សេង សឿង លេខាធិការសហជីព

៥- កញ្ញា សុខ សំអាន សមាជិកសហជីព

៦- កញ្ញា យស់ ថាវី សមាជិកសហជីព

៧- កញ្ញា ប៉ូ គន្ធា សមាជិកសហជីព

៨- កញ្ញា ដាយ វំដួល សមាជិកសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករផ្នែកកាត់ព្រុយ និងផ្នែកប៉ះពិនិត្យ ទាមទារក្រុមហ៊ុនចរចា តំលៃឡូតិ៍មុនសិន (សេរី ៣០០៩) ទើបធ្វើជាក្រោយ ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសុំឱ្យកម្មករធ្វើការងារជាមុនសិន ទើបចរចាផលិតភាពពលកម្មការងារជាក្រោយ ។

២- ភាគីកម្មករផ្នែកតម្បាញទាមទារតំលៃឡូតិ៍ PN ១២០៣០១២ A ក្នុងមួយអាវ ០.៥៩ ដុល្លា ស្មើ ៧.០៨ ដុល្លា ក្នុងមួយឡូតិ៍។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសូមរក្សាតំលៃឡូតិ៍ដូចតាមការផ្តល់ជូនកន្លងមក តម្លៃអាវមួយ ០.៥៥ ដុល្លា ស្មើ ៦.៦០ ដុល្លា ក្នុងមួយឡូតិ៍ (ខ្នាត XXS) ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ២២៧/១២ កប/កឃ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២។

THE ARBITRATION COUNCIL

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលលិខិតស្នើសុំអន្តរាគមន៍ជួយដោះស្រាយវិវាទការងារ ពីក្រុមហ៊ុន ឌីកនើធី នីតធើរ ស្តីពីកម្មករម៉ុកព្រុយនៃផ្នែកកាត់ព្រុយ និងកម្មករផ្នែកប៉ះពិនិត្យមិនគោរពតាមការចាត់តាំងការងាររបស់អ្នកគ្រប់គ្រង ហើយនាំគ្នាធ្វើកូដកម្ម។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០២ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ២២៧/១២ កប/កណ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០២ ចំណុចនេះ បន្ថែមទៀត តែមិនទទួលបានលទ្ធផលសះជាទេ។

នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។ ភាគីទាំងពីរឯកភាពពន្យាពេលនៃការចេញសេចក្តីបង្គាប់ពីថ្ងៃទី០២ ខែមេសា រហូតដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២។

នៅពេលសំណុំរឿងនេះ ត្រូវបានបញ្ជូនមកដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានកូដកម្មកើតឡើង។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជាលេខ ០០៨/១២ កបអ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ដើម្បីឱ្យកម្មករនិយោជិតចូលធ្វើការវិញនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ តទៅ តាមវេនរបស់ខ្លួន។ ជាលទ្ធផល កម្មករនិយោជិតបានចូលធ្វើការធម្មតាវិញ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបន្តនីតិវិធីអាជ្ញាកណ្តាល ជាធម្មតា។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ទស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតរបស់របស់ក្រសួងពាណិជ្ជកម្មលេខ ៤៩៦៤ ពណ.ចបព ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ជំរាបមកលោកអភិបាលក្រុមហ៊ុន ឌីកនើធី នីតធើរ ស្តីពីករណីសុំចុះបញ្ជីតម្កល់ទុកការទិញ (ACQUISITION) ភាពជាម្ចាស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ក្រុមហ៊ុន ។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ឌីកនើធី នីតធើរ ចុះខែមិថុនា ឆ្នាំ ២០១១ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វីវើរ វិច ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ។

៤- លក្ខន្តិកៈក្រុមហ៊ុន ឌីកនើធី នីតធើរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ ។

៥- សៀវភៅកត់ឡូតិ៍ផ្នែក ម៉ុក និង ដេរ ។

៦- តារាងប្រាក់ឈ្នួលប្រចាំខែ ០១ ឆ្នាំ២០១២ ។

៧- តារាងប្រាក់ឈ្នួលប្រចាំខែ ០២ ឆ្នាំ២០១២ ។

៨- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ឌីកនើធី នីតធើរ ជូបលោក តាំង ស៊ុនហេង និងលោក Jiang Wei ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ។

៩- ការពន្យល់ពីរបៀបដាក់ឡូតិ៍របស់កម្មករតម្បាញនៅក្នុងបុងឡូតិ៍ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- ការជំទាស់ឯកសារក្រុមហ៊ុន ឌីកនើធី នីតធើរ និងការបញ្ជាក់មូលហេតុរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ៣២/១២ សបក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ។

២- ស្នាមមេដៃកម្មករ កម្មការិនីផ្នែកកាត់ព្រុយ នៃរោងចក្រ ឌីកនើធី នីតធើរ ពីការបញ្ជាក់ និងបង្ហាញពីយោបល់ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ។

៣- ការប្រៀបធៀបម៉ូតចាស់ និងថ្មី ។

៤- ការពន្យល់ពីរបៀបដាក់ឡូតិ៍របស់កម្មករតម្បាញនៅក្នុងបុងឡូតិ៍ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឌីកនើធី នីតធើរ លេខ ២២៧/១២ កប/កណ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឌីកនើធី នីតធើរ ចុះថ្ងៃទី០៥ ខែមីនាឆ្នាំ ២០១២។

THE ARBITRATION COUNCIL

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៣១៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៣១៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ឌីកនេធី នីតធើរ លីមីតធីត គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ និងមានជួលកម្មករនិយោជិតចំនួនប្រមាណ ១៩០៨ នាក់។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន ឌីកនេធី នីតធើរ លីមីតធីត ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតផ្នែកកាត់ព្រុយ និងផ្នែកប៉ះពិនិត្យ ទាមទារឱ្យនិយោជកចរចាតម្លៃឡូត៍ជាមួយពួកគាត់ជាមុនសិន (ស៊េរី ៣០០៩) ទើបធ្វើជាក្រោយ

- ការអនុវត្តសព្វថ្ងៃរបស់ក្រុមហ៊ុន គឺចេញតម្លៃឡូត៍នៃស៊េរីទាំងអស់ នៅថ្ងៃទី២៥ ជារៀងរាល់ខែ ដោយហេតុថា សំលៀកបំពាក់មានប្រភេទ ច្រើនស៊េរី និងមានភាពងាយស្រួលចំពោះនិយោជក ក្នុងការកំណត់នូវការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត។ និយោជកមិនបានរៀបចំឱ្យមានការដេរសាកល្បង ដើម្បីរកមូលដ្ឋានក្នុងការកំណត់នូវតម្លៃឡូត៍នោះទេ។ ភាគីនិយោជកបញ្ជាក់ថា បើឱ្យកម្មករនិយោជិតធ្វើសាកល្បង១ថ្ងៃជាមុន នោះកម្មករនឹងឆ្លៀតឱកាសកេងយកចំណេញដោយធ្វើការយឺតៗ ដើម្បីកំណត់តម្លៃឡូត៍ទាប។
- ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា កម្មករនិយោជិតផ្នែកកាត់ព្រុយ និងផ្នែកប៉ះពិនិត្យទាមទារឱ្យនិយោជកចេញតម្លៃឡូត៍ស៊េរី៣០០៩ បន្ទាប់ពីកម្មករនិយោជិតធ្វើបាន១ថ្ងៃ ពីព្រោះនិយោជកតែងតែចេញតម្លៃឡូត៍ស៊េរីនីមួយៗ នៅថ្ងៃទី២៥ ជារៀងរាល់ខែ។ ហេតុនេះហើយ កម្មករនិយោជិតចង់ដឹងនូវតម្លៃឡូត៍បន្ទាប់ពីធ្វើឡូត៍ស៊េរី ៣០០៩ នេះបានមួយថ្ងៃ បន្ទាប់ពីចាប់ផ្តើម។ ការដឹងនូវតម្លៃឡូត៍ក្នុងអំឡុងពេលនេះ អាចធ្វើឱ្យកម្មករនិយោជិតខិតខំធ្វើការ និងមិនបារម្ភអំពីតម្លៃឡូត៍ដែលអាចទាបពេកសម្រាប់ពួកគាត់។

THE ARBITRATION COUNCIL

- ភាគីនិយោជកបានអះអាងថា ការប្រាប់នូវតម្លៃឡូត៍បន្ទាប់ពីកម្មករនិយោជិតធ្វើបានមួយថ្ងៃ គឺមិនមានភាពងាយស្រួលក្នុងការគិតប្រាក់ឈ្នួលជូនកម្មករនិយោជិតនោះទេ។ ភាគីនិយោជកបានបន្តទៀតថា រាល់ការកំណត់តម្លៃឡូត៍នីមួយៗ គឺអាស្រ័យលើប្រភេទការងារស្រួល ឬលំបាក ដើម្បីកំណត់ជាមធ្យមនូវប្រាក់ឈ្នួលរបស់កម្មករនិយោជិត។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ចំពោះស៊េរី៣០០៩ នៅក្នុងការទាមទារនេះ បានធ្វើចប់អស់ហើយ ប៉ុន្តែជាទូទៅ និយោជកតែងតែមានស៊េរី៣០០៩ សម្រាប់ឱ្យកម្មករនិយោជិតធ្វើ។ ហេតុនេះ កម្មករនិយោជិតនៅរក្សាការទាមទារឱ្យនិយោជកកំណត់តម្លៃឡូត៍ បន្ទាប់ពីបានធ្វើរយៈពេល ១ ថ្ងៃ។
- ថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត គឺនៅថ្ងៃទី២៥ នៃខែនីមួយៗ។
- ភាគីកម្មករនិយោជិតលើកឡើងថា ប្រភេទខ្លះ (ភាគច្រើន) នៃសម្លៀកបំពាក់ដែលត្រូវដេរ រួមទាំងស៊េរី៣០០៩ អាចធ្វើអស់ត្រឹមមួយអាទិត្យ ឬឆាប់ជាងនេះ ហើយប្រភេទខ្លះធ្វើត្រឹមតែ២ថ្ងៃអស់ក៏មានដែរ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករផ្នែកតម្បាញទាមទារតម្លៃឡូត៍ PN1203012A ក្នុងអាវមួយ ០.៥៩ ដុល្លារអាមេរិក ស្មើ ៧.០៨ ដុល្លារអាមេរិក ក្នុងមួយឡូត៍**

- នៅពេលសវនាការ ភាគីកម្មករនិយោជិតផ្នែកត្បាញ ទាមទារឱ្យនិយោជកតម្លើងតម្លៃឡូត៍ PN 1203012A ដោយក្នុងមួយអាវ តម្លើងឱ្យដល់តម្លៃ ០.៥៩ ដុល្លារអាមេរិក ស្មើនឹង ៧.០៨ ដុល្លារអាមេរិក ក្នុងមួយឡូត៍។
- ភាគីកម្មករនិយោជិតបានអះអាងថា PN 1203012A គឺជាម៉ូតថ្មី និងពិបាកដេរជាង PN 1090016 ប៉ុន្តែ ភាគីនិយោជកបានដាក់តម្លៃស្មើគ្នារវាង PN 1203012A និង PN 1090016។ ម្យ៉ាងវិញទៀត កម្មករនិយោជិតបានធ្វើការប្រៀបធៀបនូវចំនួនថ្ងៃចំពោះការធ្វើ PN 1203012A និង PN 1090016 គឺPN 1203012A ចំណាយពេលអស់ ៣ ទៅ ៤ថ្ងៃ ក្នុងមួយឡូត៍ និងPN 1090016 ចំណាយពេលអស់តែ ២ ទៅ ២ ថ្ងៃ កន្លះ ប៉ុណ្ណោះ។
- ភាគីនិយោជកបានបញ្ជាក់ថា PN 1203012A និងPN 1090016 មានលក្ខណៈប្រហាក់ប្រហែលគ្នា ដូចនេះហើយបានជានិយោជកកំណត់តម្លៃដូចគ្នា។ លើសពីនេះទៀត និយោជកបានបន្ថែមថា បើមើលតារាងប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅខែមករា និងខែកុម្ភៈ បានបង្ហាញថា មានកម្មករនិយោជិតផ្នែកត្បាញ (៣ នាក់ ក្នុងចំនោម ៥៨ នាក់) ដែលមានប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បបរមា ៦១ ដុល្លារអាមរិក ក្នុងមួយខែ ។
- ភាគីកម្មករនិយោជិតបានអះអាងថា ការយកប្រាក់ឈ្នួលអប្បបរមាដែលកំណត់ដោយច្បាប់ មកគិតកំណត់នូវតម្លៃដេរស៊ីបុងនេះ គឺមានលក្ខណៈមិនត្រឹមត្រូវទេ ព្រោះថា ការដេរស៊ីបុង គឺអាស្រ័យលើជំនាញ

THE ARBITRATION COUNCIL

របស់កម្មករនិយោជិតនីមួយៗ។ ដូចនេះ ភាគីកម្មករនិយជិតស្នើសុំឱ្យនិយោជកគិតពីជំនាញដែលកម្មករនិយោជិតមានក្នុងការធ្វើការងារនេះ។

**ហេតុផលនៃសេចក្ដីសម្រេច ៖**

**ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតផ្នែកកាត់ព្រុយ និងផ្នែកប៉ះពិនិត្យ ទាមទារឱ្យនិយោជកចរចាតម្លៃឡូត៍ជាមួយពួកគាត់ជាមុនសិន (ស៊េរី ៣០០៩) ទើបធ្វើជាក្រោយ**

ការអនុវត្តកន្លងមករបស់និយោជក គឺមិនដែលបានប្រាប់កម្មករនិយោជិតដឹងបន្ទាប់ពីកម្មករនិយោជិតធ្វើនូវស៊េរី៣០០៩ បាន ១ ថ្ងៃទេ ហើយថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត គឺធ្វើឡើងនៅរៀងរាល់ថ្ងៃទី២៥ នៃខែនីមួយៗ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីតម្លៃឡូត៍ ដល់កម្មករនិយោជិតក្នុងរយៈពេលប៉ុន្មានថ្ងៃ បន្ទាប់ពីកម្មករនិយោជិតចាប់ផ្ដើមធ្វើឡូត៍នោះ?

មាត្រា ១១២ នៃច្បាប់ការងារចែងថា " *និយោជកត្រូវចាត់វិធានការដើម្បីឱ្យដំណឹងដល់កម្មករនិយោជិតឱ្យបានច្បាស់ ប្រាកដ និងងាយស្រួលយល់ ៖*

*ក-អំពីល័ក្ខខ័ណ្ឌប្រាក់ឈ្នួលដែលត្រូវអនុវត្តចំពោះកម្មករនិយោជិតទាំងនោះ មុននឹងចូលកាន់តំណែងធ្វើការ ឬនៅគ្រប់ពេល ផ្លាស់ប្ដូរ ល័ក្ខខ័ណ្ឌទាំងនេះ។*

*ខ-អំពីប្រាក់ឈ្នួលទាំងអស់របស់កម្មករនិយោជិតសម្រាប់រយៈពេលបើកប្រាក់ម្ដងៗ កាលណាប្រាក់ឈ្នួលនោះអាចមានការ ផ្លាស់ប្ដូរ។"*

សំណុំរឿងលេខ ៧១/០៨-វិរីវ វីច ហេតុផលចំណុចវិវាទទី២ តាមខ្លឹមសារ និងអត្ថន័យនៃមាត្រា ១១២ នៃច្បាប់ស្ដីពីការងារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ៖ " *នៅពេលណាដែលល័ក្ខខ័ណ្ឌការងារ ជាពិសេសគឺកំរិតប្រាក់ឈ្នួលរបស់កម្មករនិយោជិតប្រែប្រួល និយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតឱ្យច្បាស់លាស់អំពីប្រាក់ឈ្នួលដែលគេនឹងបានទទួលនាពេលខាងមុខ។ ផ្អែកលើការបកស្រាយនេះ ការទាមទាររបស់ភាគីកម្មករនិយោជិត ពាក់ព័ន្ធនឹងសិទ្ធិដែលកំណត់ដោយច្បាប់ស្ដីពីការងារ ដែលតម្រូវឱ្យនិយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីល័ក្ខខ័ណ្ឌប្រាក់ឈ្នួលដល់កម្មករនិយោជិត។*"

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយខាងលើនេះដែរ។ ក្នុងករណីនេះ កម្មករនិយោជិតធ្វើការងារដេរស៊ីឡូត៍ ហេតុនេះ ប្រាក់ឈ្នួលរបស់គាត់តែងតែមានការប្រែប្រួលទៅតាមប្រភេទឡូត៍នីមួយៗដែលកម្មករនិយោជិតធ្វើ។ ដូចនេះ និយោជកមានកាតព្វកិច្ចជូនដំណឹងទៅកម្មករនិយោជិតអំពីប្រាក់ឈ្នួលរបស់ពួកគាត់ក្នុងករណីមានការប្រែប្រួលនៅពេលគាត់ដេរប្រភេទឡូត៍ខុសៗគ្នា។

ក្នុងសំណុំរឿងនេះ ភាគីនិយោជកតែងប្រាប់កម្មករនិយោជិតអំពីតម្លៃឡូត៍គ្រប់ស៊េរីទាំងអស់ នៅថ្ងៃទី២៥ នៃខែនីមួយៗ រួមទាំងស៊េរី ៣០០៩ នេះផង។ រាល់ការកំណត់តម្លៃឡូត៍នីមួយៗ គឺអាស្រ័យលើប្រភេទការងារស្រួល ឬលំបាក ដើម្បីកំណត់ជាមធ្យមនូវប្រាក់ឈ្នួលរបស់កម្មករនិយោជិត។ ពោលគឺ និយោជកឱ្យកម្មករនិយោជិតទាំងអស់ធ្វើរួចហើយ ទើបនិយោជកគិតគូរ និងថ្លឹងថ្លែងទៅលើសមត្ថភាព និងកំលាំងពលកម្មរបស់កម្មករនិយោជិតក្នុងការដាក់តម្លៃឡូត៍មួយឱ្យបានត្រឹមត្រូវសមរម្យ។

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការចេញតម្លៃឡូត៍នៅថ្ងៃទី២៥ ជារៀងរាល់ខែនេះ គឺប៉ះចំថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតតែម្តង ដែលវាមិនស្របទៅនឹងគោលបំណងរបស់មាត្រា ១១២ ដែលតម្រូវឱ្យនិយោជកចាំបាច់ត្រូវជូនដំណឹងដល់កម្មករនិយោជិត ឱ្យដឹងច្បាស់អំពីប្រាក់ឈ្នួលដែលពួកគាត់នឹងត្រូវទទួលបាននាពេលខាងមុខ ជាពិសេសចំពោះការកម្រិតប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលអាចមានការប្រែប្រួល ឬផ្លាស់ប្តូរដូចជា ក្នុងករណីប្រាក់ឈ្នួលតាមបរិមាណផលិតផលនេះជាដើម។ ទន្ទឹមនឹងនេះដែរ និយោជកអាចជ្រើសរើសកម្មករជំនាញ ដើម្បីធ្វើជាក្រុមដេរសាកល្បងក្នុងរយៈពេលដ៏សមរម្យមួយ មុននឹងសម្រេចចេញតម្លៃឡូត៍ជូនកម្មករនិយោជិត។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា រយៈពេលទូទៅសម្រាប់កំណត់តម្លៃឡូត៍ គឺពី ៣ ទៅ ៧ ថ្ងៃ (១សប្តាហ៍) អាស្រ័យលើភាពងាយស្រួល ឬលំបាកនៃការងារ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៥/០៦-ដាប់ប៊ីល យូ អ៊ែន់ ឌី ហេតុផលចំណុចវិវាទទី៧ និងលេខ ៨១/០៩-វីន រេច ហេតុផលចំណុចវិវាទទី១១)*។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របថា រយៈពេលពី ៣ ទៅ ៧ ថ្ងៃ (១សប្តាហ៍) គឺជារយៈពេលដ៏សមស្របមួយដែលនិយោជកអាចមានលទ្ធភាពវាស់ស្ទង់អំពីសមត្ថភាពរបស់កម្មករនិយោជិតថា តើពួកគាត់អាចដេរបានក្នុងកម្រិតណា ហើយគាត់គួរកំណត់តម្លៃឡូត៍ចំនួនប៉ុន្មាន ដើម្បីឱ្យបានស្របនឹងច្បាប់ស្តីពីការងារផង។

នៅក្នុងករណីនេះ ភាគីនិយោជកបានលើកឡើងថា ការកំណត់តម្លៃឡូត៍នៅរៀងរាល់ថ្ងៃទី២៥ នៃខែនីមួយៗ គឺមានភាពងាយស្រួលសម្រាប់គាត់ក្នុងការគិតប្រាក់ឈ្នួលជូនកម្មករនិយោជិត ប៉ុន្តែ និយោជកមិនបានបញ្ជាក់អំពីភាពខុសគ្នាដែលអាចកើតមានឡើងចំពោះប្រភេទឡូត៍ដែលខុសគ្នា ឬដែលអាចស្រួល ឬពិបាកធ្វើជាងគ្នានោះទេ។ ពោលគឺ និយោជកកម្រិតថ្ងៃចេញតម្លៃឡូត៍នៅរៀងរាល់ថ្ងៃទី២៥ នេះ សម្រាប់គ្រប់ប្រភេទឡូត៍ទាំងអស់តែម្តង និងដោយមិនមានការដេរសាកល្បង ដើម្បីយកជាមូលដ្ឋានក្នុងការកំណត់នូវតម្លៃឡូត៍នោះទេ។ ដោយសារប្រភេទខ្លះនៃសម្លៀកបំពាក់ដែលត្រូវដេរ រួមទាំងស៊េរី៣០០៩ ផង អាចធ្វើអស់ត្រឹមមួយអាទិត្យ ឬឆាប់ជាងនេះ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា រយៈពេល៣ថ្ងៃ គឺមានការសមស្របសម្រាប់ភាគីទាំងពីរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកជូនដំណឹងដល់កម្មករនិយោជិតផ្នែកកាត់ព្រុយ និងផ្នែកប៉ះពិនិត្យ អំពីតម្លៃឡូត៍ចំពោះស៊េរី៣០០៩ បន្ទាប់ពីកម្មករនិយោជិតធ្វើបាន ៣ ថ្ងៃ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករផ្នែកតម្បាញទាមទារតម្លៃឡូត៍ PN1203012A ក្នុងអាវមួយ ០.៥៩ ដុល្លារអាមេរិក ស្មើ ៧.០៨ ដុល្លារអាមេរិក ក្នុងមួយឡូត៍**

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកតម្លើងតម្លៃឡូត៍ PN1203012A ឱ្យគ្រប់ ០.៥៩ ដុល្លារអាមេរិក ក្នុងមួយអាវ ដោយអះអាងថា មានការលំបាកចំពោះការដេរ ជាពិសេស បើប្រៀបធៀបនឹង PN 1090016។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណា តើនិយោជកមានកាតព្វកិច្ចក្នុងការតម្លើងតម្លៃឡូត៍ PN 1203012A នេះ ឱ្យគ្រប់ ០.៥៩ ដុល្លារអាមេរិកក្នុងមួយអាវដែរ ឬទេ?

មាត្រា ១០៨ នៃច្បាប់ស្តីពីការងារចែងថា *“ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផល ទោះធ្វើនៅរោងជាង ឬ នៅលំនៅក៏ដោយ ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឱ្យកម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យមធ្វើការជាធម្មតាបានទទួលក្នុងចិរវេលាធ្វើការដដែលនូវប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិត”* ។

ចំណុចទី៣ នៃសេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/ស.ជ.ណ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ ចែងថា *“៣. ចំពោះកម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) ត្រូវបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបាននោះ លើសពីចំនួនប្រាក់ឈ្នួលដែលមានចែងក្នុងចំណុចទី២ ខាងលើ ត្រូវទទួលបានតាមការលើសនោះ ។ ប្រសិនបើទាបជាង និយោជកត្រូវបន្ថែមឱ្យគ្រប់ចំនួន ៥៦ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតធ្វើការសាកល្បង និងចំនួន ៦១ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ”* ។

នៅក្នុងសេចក្តីបង្គាប់មុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា *“និយោជកមានសិទ្ធិកំណត់ ឬផ្លាស់ប្តូរតម្លៃប៉ុង ក៏ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចថា ត្រូវកំណត់ធ្វើយ៉ាងណាឱ្យតម្លៃប៉ុងឱ្យកម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យម ធ្វើការធម្មតាអាចទទួលបានប្រាក់ឈ្នួលអប្បបរមា”* ។ *(សូមមើលសំណុំរឿងលេខ ០៣/០៥-ហ្គាយអ៊ីង ដ្រាហ្គុង ចំណុចវិវាទទី៦, លេខ ៤១/០៥-វ៉ាយអូលែត ចំណុចវិវាទទី៨ និងលេខ ៤៤/០៦-ហ្គោលហ្វេម ចំណុចវិវាទទី១)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របជាមួយនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

តាមរយៈភស្តុតាងតារាងប្រាក់ឈ្នួលប្រចាំខែមករា និងខែកុម្ភៈ បានបញ្ជាក់ថា កម្មករនិយោជិតផ្នែកត្បាញដែលដេរស៊ីប៉ុង មានចំនួន ៥.១៧ ភាគរយ នៃចំនួនកម្មករនិយោជិតផ្នែកត្បាញទាំងអស់ ដែលដេរតាមម៉ោងការងារធម្មតា មិនបញ្ចូលការងារថែមម៉ោង ទទួលបានប្រាក់ឈ្នួលគោលទាបជាងប្រាក់ឈ្នួលអប្បបរមា ៦១ ដុល្លារអាមេរិក ក្នុងមួយខែ និងមានចំនួន ៩៤.៨៣ ភាគរយ នៃកម្មករនិយោជិតនៃផ្នែកត្បាញទទួលបានប្រាក់ឈ្នួលលើសពីប្រាក់ឈ្នួលអប្បបរមា ៦១ ដុល្លារអាមេរិក ក្នុងមួយខែ ។ ចំពោះកម្មករនិយោជិតដែលដេរបានទាបជាងប្រាក់ឈ្នួលអប្បបរមា គឺនិយោជកបានបង្គ្រប់ឱ្យដល់ប្រាក់ឈ្នួលអប្បបរមាហើយ ។ ក៏ប៉ុន្តែ ដើម្បីឱ្យការកំណត់តម្លៃឡូតិ៍បានត្រឹមត្រូវ និងសមស្របតាមច្បាប់ នោះនិយោជកត្រូវរៀបចំឱ្យមានការធ្វើការងារសាកល្បងក្នុងរយៈពេលសមស្របមួយ ដូចបានពន្យល់ក្នុងចំណុចវិវាទទី១ ខាងលើ ដើម្បីធានាថា កម្មករដែលមានការប៉ិនប្រសប់មធ្យម ធ្វើការធម្មតាអាចទទួលបានប្រាក់ឈ្នួលអប្បបរមាតាមផ្លូវច្បាប់ ។

ក្នុងករណីនេះ មូលហេតុដែលកម្មករនិយោជិតទាមទារឱ្យនិយោជកតម្លើងតម្លៃឡូតិ៍ ០.៥៥ ដុល្លារអាមេរិក ក្នុងមួយអាវឱ្យដល់ ០.៥៩ ដុល្លារអាមេរិក គឺព្រោះថា ពួកគាត់សុទ្ធតែមានជំនាញលើការងារនេះ ។

មាត្រា ២ កថាខ័ណ្ឌ ២ នៃច្បាប់ស្តីពីការងារចែងថា *“សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នា ក្នុងទីកន្លែងណាមួយជាក់លាក់ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក”* ។

THE ARBITRATION COUNCIL

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា មាត្រា ២ នៃច្បាប់ស្តីពីការងារនេះមានន័យថា ភាគីនិយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ឱ្យតែសិទ្ធិនេះមានលក្ខណៈស្របច្បាប់ និងសមហេតុសមផល។ (សូមមើលសេចក្តីបង្គាប់លេខ ៤៧/០៨-ហ្វែ្រន ចិច ហេតុផលចំណុចវិវាទទី២ ,លេខ ៥៣/០៩-តាក ហ្វាត ហេតុផលចំណុចវិវាទទី២ និងលេខ ១៥១/១១ ហ្រ្គេត អននើរ ថេកស្តាយ) ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការចាត់ចែងរបស់និយោជកបានកំណត់នូវការកំណត់តម្លៃឡូត៍ឱ្យកម្មករនិយោជិតផ្នែកត្បាញធ្វើ គឺមានលក្ខណៈស្របច្បាប់ និងសមហេតុផល ព្រោះថា ការកំណត់តម្លៃនេះ បានធ្វើឱ្យកម្មករនិយោជិតភាគច្រើនបានទទួលនូវប្រាក់ឈ្នួលដែលលើសពីប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ដោយច្បាប់។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិតផ្នែកត្បាញឱ្យនិយោជកតម្លើងតម្លៃឡូត៍ PN 1203012A ដោយក្នុងមួយអាវ ០.៥៩ ដុល្លារអាមេរិក ស្មើ ៧.០៨ ដុល្លារអាមេរិក ក្នុងមួយឡូត៍។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១៖**

បង្គាប់ឱ្យនិយោជកជូនដំណឹងដល់កម្មករនិយោជិតផ្នែកកាត់ព្រុយ និងផ្នែកប៉ះពិនិត្យ អំពីតម្លៃឡូត៍ចំពោះស៊េរី ៣០០៩ បន្ទាប់ពីកម្មករនិយោជិតធ្វើបាន ៣ ថ្ងៃ។

**ចំណុចវិវាទទី ២៖**

បដិសេធការទាមទាររបស់កម្មករនិយោជិតផ្នែកត្បាញ ឱ្យនិយោជកតម្លើងតម្លៃឡូត៍ PN1203012A ដោយក្នុងមួយអាវ ០.៥៩ ដុល្លារអាមេរិក ស្មើ ៧.០៨ ដុល្លារអាមេរិក ក្នុងមួយឡូត៍។

**ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយអនុលោមតាមការយល់ព្រមជ្រើសរើសរបស់ភាគីទាំងពីរថា យកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចទៅក្នុងសវនាការ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២។*

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទួន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL